## ៧- ធម៌ផ្សាយចំណែកបុណ្យ

មុននឹងចប់ពិធីបុណ្យ គេតែងសូត្រធម៌ផ្សាយចំណែកបុណ្យ ជូន លោក អ្នក មានគុណ មាន មាតា បិតា ជីដូន ជីតា និង ញាតិមិត្រ ជាដើម ដូចតទៅនេះ ៖

**-យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** អំពើជាកុសល ឯណាមួយ ដែលខ្ញុំ គប្បីធ្វើ, ដោយទ្វារទាំង៣ គឺ

**-កាយេន វាចា មនសា** កាយ វាចា ចិត្ត,

**-តិទសេ សុគតំ កតំ,** អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឲ្យទៅកើតក្នុងស្ថានត្រៃត្រឹង្ស សុគតិ បាន,

**-យេ សត្តា សញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណា គឺ មនុស្ស ឬ ទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី,

**-យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយឯណា ជា អសញ្ញីសត្វ គឺសត្វដែលឥតសញ្ញាក្តី,

**-កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** សត្វទាំងឡាយទាំងអស់នោះ ចូរបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យដែលខ្ញុំបានធ្វើហើយបានឧទ្ទិសផ្សាយឲ្យទៅនោះចុះ,

**-យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឲ្យបានសោយនូវផលនៃបុណ្យដែលខ្ញុំ បានឧទ្ទិសឲ្យទៅនោះចុះ,

**-យេ ច តត្ថ ន ជានន្តិ** ម្យ៉ាងទៀត បណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយ

*ឯណា មិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ,*

**-ទេវា គន្ត្វា និវេទយុំ** *សូមទេវតាទាំងឡាយ អញ្ជើញទៅឲ្យដំណឹង ដល់សត្វទាំងឡាយនោះ ឲ្យបានដឹងផង ថាជនឯណោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ,*

**-សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** *សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារ ហើយរស់នៅ,*

**-មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។** *សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយ បុញ្ញឫទ្ធិ តាមចិត្តខ្ញុំដែលឧទ្ទិសផ្សាយឲ្យទៅនោះចុះ ៕*

*វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។*